ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

លេខ:០១៣.ជនស/អរប

រាជធានីភ្នំពេញ, ថ្ងៃទី២៤...ខែមីនា ឆ្នាំ២០១៦

# របាយការណ៍
## អំពីលទ្ធផលនៃការពិភាក្សាក្នុងអង្គសន្និបាតបូកសរុបការងារឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កាលពីថ្ងៃទី២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ ក្រោមអធិបតីភាពឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដោយមានការអញ្ជើញចូលរួមជាគណៈអធិបតីពីឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងមានការចូលរួមពីឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋាន/អង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី សរុបចំនួន១៦០នាក់។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានផ្តល់អនុសាសន៍ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបន្តពង្រឹងស្មារតីសាមគ្គីឯកភាព និងសហការគ្នាល្អក្នុងក្របខ័ណ្ឌក្រសួងនីមួយៗ ក៏ដូចជារវាងក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ ខិតខំសម្រេចការងាររបស់ខ្លួន ក្នុងស្មារតីជំរុញការកែទម្រង់កាន់តែស៊ីជម្រៅតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រីគឺ "ធ្វើឱ្យបាន ធ្វើឱ្យលឿន ធ្វើឱ្យមានតម្លាភាព" នូវសេវាសាធារណៈក្នុងសមត្ថកិច្ចរបស់ក្រសួងស្ថាប័ននីមួយៗ ពិសេសត្រូវផ្តោតលើសេវាសាធារណៈដែលជាតម្រូវការរបស់ប្រជាពលរដ្ឋតាមការកំណត់របស់ច្បាប់។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានណែនាំឱ្យពិភាក្សានូវបញ្ហាដូចជា **សិទ្ធិកម្មសិទ្ធិរបស់ប្រជាជនលើដីធ្លី ការងារសម្បទានដីសង្គមកិច្ច ការងារលំនៅឋាន** សម្រាប់អ្នកមានចំណូលទាប និងមធ្យម **ការងារនគរូបនីយកម្មនិងសំណង់ ការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ**។ ដោយឡែកក្នុងក្របខ័ណ្ឌនៃការធ្វើសមាហរណកម្មសហគមន៍អាស៊ាន ក្រសួង រៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មានពាក់ព័ន្ធនឹងជំនាញចំនួន០៣ ដែលត្រូវបានទទួលស្គាល់គ្នាទៅវិញទៅមក រវាងប្រទេសអាស៊ានទាំង១០ គឺការងារវិស្វកម្ម ស្ថាបត្យកម្ម និងការវាស់វែងដីធ្លីដែលតម្រូវឱ្យយកចិត្តទុកដាក់លើការធ្វើសមាហរណកម្មផ្នែកទន់ ដូចជាការរៀបចំកសាងក្របខណ្ឌគោលនយោបាយ ច្បាប់ និងប្រព័ន្ធស្តង់ដារចាំបាច់នានា ក៏ដូចជាធ្វើពិពិធកម្ម និងការពង្រឹងអាជីពវិជ្ជាជីវៈនានា និងបណ្តុះបណ្តាលធនធានមនុស្ស។/.

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel / Fax : 023 215 279 / (855-23) 215 660 គេហទំព័រ www.mlmupc.gov.kh /

អង្គសន្និបាតក៏បានពិភាក្សាទៅលើបញ្ហាចំនួន១០ រួមមាន ទី១)-ការងាររដ្ឋបាលដីធ្លី ២)-ការងារភូមិសាស្ត្រ ៣)-ការងារដោះស្រាយវិវាទដីធ្លី ៤)-ការងារសំណង់ ៥)-ការងារសម្បទានដីសង្គមកិច្ច ៦)-ការងារអភិវឌ្ឍន៍តំបន់ឆ្នេរ ៧)-ការងាររៀបចំដែនដី ៨)-ការងារលំនៅឋាន ៩)-ការងារច្បាប់ និង១០)-ការងាររដ្ឋបាលទូទៅនិងយេនឌ័រ។ អង្គសន្និបាតបានសម្រេចដូចខាងក្រោម៖

## I- លើការងាររដ្ឋបាលដីធ្លី

១- ស្នើពិនិត្យបន្ថែមឲ្យបានល្អិតល្អន់លើគ្រប់ទិដ្ឋភាព និងគ្រប់ជ្រុងជ្រោយអំពីផលវិបាកនិងបញ្ហាប្រឈមនានាដែលនឹងកើតមានចំពោះការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដែលតម្រូវឲ្យទៅបង់ពន្ធប្រថាប់ត្រាជាមុន ចំពោះការផ្ទេរសិទ្ធិលើដីដែលគ្មានប័ណ្ណ (តាមលិខិតលេខ១៣៤សជណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ដើម្បីមានមូលដ្ឋានពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលើកសំណើទៅរាជរដ្ឋាភិបាល

២- រាល់ការស្នើសុំកាត់ដី និងអនុបយោគដីសម្រាប់យកទៅធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ អាជ្ញាធរខេត្តត្រូវធ្វើសំណើត្រង់មកក្រសួងដែលមានអាណត្តិកាន់កាប់ដី ហើយពេលក្រសួងដែលមានអាណត្តិកាន់កាប់ដីឆ្លើយតបទៅសាមីខេត្តវិញ ត្រូវចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

៣- ត្រូវជម្រះទិន្នន័យកកស្ទះក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងធ្វើការវាយតម្លៃឱ្យបានក្នុងឆមាសទី១ ឆ្នាំ២០១៦។ ចំណែកទិន្នន័យដែលបានកកស្ទះពីបទបញ្ជាលេខ ០១បប ប្រមាណ៥ម៉ឺនក្បាលដី សុំឲ្យអាជ្ញាធរខេត្ត ពិនិត្យសម្រេចឲ្យបានឆាប់ រួចលើកសំណើសុំការសម្រេចពីរាជរដ្ឋាភិបាល

៤- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ត្រូវលើកគម្រោងសុំអគារ និងសម្ភារៈសម្រាប់ទុកដាក់ឯកសារសុរិយោដី

៥- ត្រូវរៀបចំផែនការធ្វើការផ្ទៀងផ្ទាត់ចំនួនក្បាលដីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំតាមរាជធានី-ខេត្ត ដើម្បីដកតួលេខចំនួនក្បាលដីចេញពីស្ថិតិរួម

៦- រៀបចំប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យសុរិយោដីមួយថ្មីដើម្បីបំពេញចំណុចខ្វះខាតឱ្យស្របតាមក្រមរដ្ឋប្បវេណី និងអាចប្រមូលផ្តុំទិន្នន័យចុះបញ្ជីដីធ្លីទូទាំងប្រទេសនៅថ្នាក់ជាតិ ដែលផ្តល់ភាពងាយស្រួល និងឆាប់រហ័សក្នុងការស្វែងរកព័ត៌មាន ក៏ដូចជាផ្តល់នូវព័ត៌មានទាន់ពេលវេលា

៧- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវលើកផែនការថវិកាដើម្បីបោះពុម្ពសម្រង់ឯកសារសុរិយោដី (ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី) ជូនរដ្ឋបាលឃុំ សង្កាត់

៨- ក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនីមួយៗតាមបណ្តារាជធានី ខេត្ត ត្រូវរៀបចំសមាជិក០១ឬ០២នាក់ ដើម្បីបន្តដោះស្រាយតាមក្រោយ និងរៀបចំផែនការជម្រះឱ្យដាច់ស្រេចនូវទិន្នន័យកកស្ទះទាក់ទងនឹងទំនាស់ដីធ្លីក្នុងតំបន់វិនិច្ឆ័យ

៩- ជំរុញដោះស្រាយបន្ទាន់នូវការកាន់កាប់ដីរបស់ប្រជាពលរដ្ឋលើទីតាំងដីឯកជនរបស់រដ្ឋតាមបណ្តារាជធានី ខេត្ត និងត្រូវធ្វើរបាយការណ៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

## II- ការងារភូមិសាស្ត្រ

- ត្រូវរៀបចំប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបានកំណត់ដោយអនុក្រឹត្យស្តីពីគ្រប់គ្រងលើការវាស់វែង និងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី

និងកំណត់នីតិវិធីសម្រាប់ការវាយតម្លៃទទួលស្គាល់សមត្ថភាពវាស់វែងរបស់អ្នកស្នើសុំ និងការធ្វើសមាហរណកម្មជំនាញឱ្យក្លាយជាអ្នកវាស់វែង

- កំណត់ស្តង់ដាក្នុងការវាស់វែងនិងការផលិតផែនទីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានការកំណត់ Datum និងធ្វើបច្ចុប្បន្នភាពទិន្នន័យផែនទីគោលសម្រាប់ការផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការ
- ផ្តល់វិញ្ញាបនបត្រវាស់វែង និងអាជ្ញាប័ណ្ណវាស់វែងដល់អ្នកវាស់វែងនិងក្រុមហ៊ុនវាស់វែងសំដៅធានានូវការផលិត ការប្រើប្រាស់ និងការគ្រប់គ្រងទិន្នន័យវាស់វែងនិងផលិតផែនទី ប្រកបដោយសុក្រឹតភាពនិងប្រសិទ្ធភាព។

## III -ការងារដោះស្រាយវិវាទដីធ្លី

១-គណៈកម្មការសុរិយោដីរាជធានី ខេត្ត ត្រូវសម្រេចឱ្យបានការសម្រុះសម្រួលករណីវិវាទពី ១០ ទៅ១៥ករណីក្នុង១រាជធានី-ខេត្ត ក្នុង១ឆ្នាំ។ ដោះស្រាយបញ្ចប់ដោយការសម្រុះសម្រួលការចេញសេចក្តីសម្រេច ឬបញ្ជូនទៅថ្នាក់ជាតិពី៥ទៅ៧សំណុំរឿង ក្នុង១រាជធានី ខេត្ត ក្នុង១ឆ្នាំ

២-គណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចឱ្យបាននូវការកសាងសំណុំរឿងនិងធ្វើការសម្រុះសម្រួលឱ្យបានពី៣ទៅ៥ករណីក្នុង១ក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលបញ្ចប់ ឬបញ្ជូនសំណុំរឿងទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តឱ្យបានពី២ ទៅ ៣ករណី ក្នុង១ ក្រុង ស្រុក ខណ្ឌ ក្នុង១ឆ្នាំ

៣-គណៈកម្មការរដ្ឋបាល មុននឹងធ្វើរបាយការណ៍បញ្ចប់លទ្ធផលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវកសាងសំណុំរឿងវិវាទបឋម និងធ្វើកំណត់ហេតុប្រជុំដោះស្រាយ១ដងយ៉ាងតិចក្នុង១ករណី

៤-គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់ពង្រឹងលេខាធិការដ្ឋានគណៈកម្មការសុរិយោដី ដែលជាសេនាធិការរបស់ខ្លួនដោយដាក់ផែនការកម្មវិធីត្រួតពិនិត្យតាមដានសកម្មភាពការងារ និងវាយតម្លៃលទ្ធផលការងារដែលសម្រេចបានជាប្រចាំ និងលើកកម្ពស់ស្មារតីទទួលខុសត្រូវលើការងារដោះស្រាយវិវាទដីធ្លីជាប្រចាំយ៉ាងតិច១ខែ ប្រជុំជាមួយមន្ត្រីលេខាធិការដ្ឋានម្តង ដើម្បីពិនិត្យលទ្ធផលនិងដាក់វិធានការ និងចាត់ចែងការងារដោះស្រាយបន្ត។

## IV-ការងារសំណង់ និងការងារស្ថាបត្យកម្ម

### ១-ការងារសំណង់

- ត្រូវបន្តសហការជាមួយក្រុមការងារអភិវឌ្ឍ និងផ្សព្វផ្សាយគោលនយោបាយ និងច្បាប់ ក្នុងការរៀបចំផែនការដោយកំណត់កាលបរិច្ឆេទច្បាស់លាស់អំពីកម្មវិធីប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់លើការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីបញ្ចប់សេចក្តីព្រាងច្បាប់សំណង់ ប្រកាស ស្តីពីប្រព័ន្ធការងារគ្រប់គ្រងគម្រោងសាងសង់ ប្រកាសស្តីពីការគ្រប់គ្រងក្រុមជាងជំនាញវិស័យសំណង់ ការកែសម្រួលអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ ការកែសម្រួលប្រកាសស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគម្រោង និងការកែសម្រួលប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ត្រូវរៀបចំផែនការផ្សព្វផ្សាយ និងធ្វើការណែនាំអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសំណង់ សុវត្ថិភាពក្នុងវិស័យសំណង់ និងផលវិបាកនៃការសាងសង់ដែលមិនគោរពទៅតាមច្បាប់ និងបទដ្ឋានគតិយុត្ត ដោយត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិចឱ្យបានមួយដងក្នុងមួយឆ្នាំនៅតាមបណ្តាខេត្ត ដោយឡែកចំពោះរាជធានីភ្នំពេញ និងខេត្តដែលវិស័យសំណង់មានការអភិវឌ្ឍន៍ខ្លាំងត្រូវរៀបចំកិច្ចប្រជុំឱ្យបានយ៉ាងតិចពីរដងក្នុង១ឆ្នាំ។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះត្រូវមានមន្ត្រីជំនាញនៃមន្ទីរជនសស មន្ទីរនិងអង្គភាពនានាជុំវិញខេត្ត រដ្ឋបាល

ថ្នាក់ ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសំណង់ និងអ្នកអភិវឌ្ឍន៍អចលនវត្ថុ

- បង្កើនការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ឱ្យមានប្រសិទ្ធភាពដោយត្រូវធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តដែលមាន ឱ្យស្របតាមសភាពការណ៍បច្ចុប្បន្នក្នុងពេលដែលវិស័យសំណង់កំពុងមានការរីកចម្រើនខ្លាំងឈានដល់ការសាងសង់អគារទំនើប និងខ្ពស់ៗ និងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ត្រូវតែចុះត្រួតពិនិត្យគ្រប់ការដ្ឋានសំណង់ជាប្រចាំទាំងសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងទាំងសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយសាលារាជធានី ខេត្ត តាំងពីពេលចាប់ផ្តើមបើកការដ្ឋាន អំឡុងពេលសាងសង់ និងក្រោយពេលសាងសង់ដើម្បីឱ្យប្រាកដថាសំណង់ត្រូវបានសាងសង់ដោយគោរពទៅតាមប្លង់ស្ថាបត្យកម្ម មានលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងលិខិតបិទការដ្ឋាន មុននឹងសំណង់ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវរាយការណ៍ និងលើកយោបល់ជាបន្ទាន់ជូនសាលារាជធានី ខេត្ត និង/ឬជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នូវរាល់អំពើល្មើសសំណង់ដែលបាននិងកំពុងកើតឡើង ពិសេសសំណង់ដែលបានសាងសង់រំលោភលើដីសាធារណៈ ចំណីផ្លូវ និងសួនច្បារសាធារណៈ ដើម្បីថ្នាក់ដឹកនាំមានវិធានការជាក់ស្តែងទាន់ពេលវេលា
- ណែនាំឱ្យសហគ្រាស ក្រុមហ៊ុនម៉ៅការសាងសង់ ត្រូវទទួលបន្ទុកដាក់បង្ហាញស្លាកសញ្ញាស្តីពីសុវត្ថិភាពនៅការដ្ឋានសំណង់ដែលសាធារណជនទូទៅងាយមើលឃើញនិងត្រូវរៀបចំប្រជុំណែនាំដល់បុគ្គលិកកម្មករជាប្រចាំអំពីសុវត្ថិភាពការងារក្នុងការដ្ឋាន និងវិធានការក្នុងការជម្លៀសមនុស្សពីឧប្បត្តិហេតុផ្សេងៗដែលកើតឡើងជាយថាហេតុក្នុងការដ្ឋាន។

## ២-**ការងារស្ថាបត្យកម្ម**

- ពន្លឿនការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបន្ថែមទៀតដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍វិស័យស្ថាបត្យកម្មប្រកបដោយនិរន្តរភាពដូចជា សេចក្តីព្រាងស្តង់ដារស្ថាបត្យកម្ម និងសេចក្តីព្រាងប្រកាសស្តីពីការកំណត់តម្លៃសេវាលើការសិក្សាគម្រោងប្លង់ស្ថាបត្យកម្មរបស់ក្រុមហ៊ុន ឬរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- ជំរុញដល់អ្នកប្រកបវិជ្ជាជីវៈវិស័យស្ថាបត្យកម្ម ត្រូវតែទៅចុះបញ្ជីដើម្បីទទួលបានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈខាងវិស័យស្ថាបត្យកម្មពីគណៈស្ថាបត្យករកម្ពុជា
- ផ្សព្វផ្សាយច្បាប់ អនុក្រឹត្យ បទដ្ឋានគតិយុត្ត និងស្តង់ដារស្ថាបត្យកម្មពាក់ព័ន្ធវិស័យស្ថាបត្យកម្មដល់មន្ត្រីជំនាញ និងអាជ្ញាធរដែនដី ពិសេសប្រជាពលរដ្ឋ និងម្ចាស់សំណង់
- ខិតខំណែនាំម្ចាស់សំណង់ឱ្យយល់ដឹងអំពីលក្ខណៈស្ថាបត្យកម្មខ្មែរ និងផលវិបាកនៃការសាងសង់មិនមានគម្រោងប្លង់ស្ថាបត្យកម្ម ឬការសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម ដែលមិនមែនជាស្ថាបត្យករ។

## V-**ការងារសម្បទានដីសង្គមកិច្ច**

- ជំរុញឲ្យបង្កើតជាភូមិផ្លូវការចំពោះទីតាំងសម្បទានដីសង្គមកិច្ចចំនួន១១កន្លែង ដែលបានបែងចែករួចនិងដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍប្រចាំឆ្នាំរបស់ឃុំ
- ត្រូវបន្តស្រង់ទិន្នន័យសម្បទាននិកតាមទីតាំង ដែលបានបែងចែករួចដែលឈានដល់គ្រប់រយៈពេល៥ឆ្នាំ ដើម្បីបំពេញបែបបទចុះបញ្ជីផ្តល់ប័ណ្ណកម្មសិទ្ធិដីជូនពួកគាត់ ៥

- ស្រង់ទិន្នន័យដីរដ្ឋដែលនៅសល់ជាក់ស្តែងក្នុងទីតាំង៤៩កន្លែងក្នុងខេត្តចំនួន១៦ ដែលមានដីបម្រុងទុកពីពេលមុនទំហំ ១៣៤.០០០ហិកតា ដើម្បីកំណត់ច្បាស់លាស់ និងការពារឲ្យបានសម្រាប់គោលដៅសម្បទានសង្គមកិច្ច
- បន្តរៀបចំបញ្ចប់ផែនការប្រើប្រាស់ដីនិងប្លង់បែងចែកដីឡូត៍កសិកម្មនិងដីឡូត៍លំនៅឋាននៅទីតាំងដីសម្បទានសង្គមកិច្ចនៅក្នុងខេត្តរតនគីរី និងខេត្តស្ទឹងត្រែង
- ជំរុញអាជ្ញាធរថ្នាក់ក្រោមជាតិធ្វើការដោះស្រាយទំនាស់ដីធ្លី និងថែរក្សាដីដែលបានធ្វើអត្តសញ្ញាណកម្មទុកសម្រាប់កម្មវិធីសម្បទានដីសង្គមកិច្ច
- ជំរុញឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិខិតខំធ្វើអត្តសញ្ញាណកម្មមុខសញ្ញាអ្នកដែលខ្វះដី និងត្រូវការដីពិតប្រាកដដោយត្រួតពិនិត្យ និងស្រាវជ្រាវដល់មូលដ្ឋានដើមរបស់អ្នកស្នើសុំដី
- ធ្វើសន្និធិដីដែលទទួលបានពីការលុបចោលកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ដើម្បីបម្រើឲ្យកម្មវិធីសម្បទានដីសង្គមកិច្ច។

## VI-ការងារអភិវឌ្ឍតំបន់ឆ្នេរ

- ជំរុញរៀបចំផែនការប្រើប្រាស់និងកំណត់បែងចែកតំបន់បឹងព្រៃកទប់ ព្រមទាំងសេចក្តីព្រាងព្រះរាជក្រឹត្យឱ្យចប់ស្គាពរ ដើម្បីស្នើសុំរាជរដ្ឋាភិបាលសម្រេចដាក់តំបន់បឹងទឹកសាបព្រៃកទប់ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន
- ជំរុញរៀបចំប្លង់មេសមាហរណកម្មអភិវឌ្ឍតំបន់ឆ្នេរឯករាជ្យ ដើម្បីឱ្យសាធារណជនអាចចេញចូលលំហែកម្សាន្តបាន និងប្រព័ន្ធគ្រប់គ្រងច្បាស់លាស់
- ជំរុញការរៀបចំប្លង់មេសមាហរណកម្ម អភិវឌ្ឍឆ្នេរគម្រូអូរត្រេះ និងសំណើជម្រើសដំណោះស្រាយ ព្រមទាំងប្រព័ន្ធគ្រប់គ្រងដើម្បីដាក់ស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- ជំរុញរៀបចំប្លង់មេសមាហរណកម្មអភិវឌ្ឍតំបន់ឆ្នេរអូរឈើទាល (អារីស្កុន) និងប្រព័ន្ធគ្រប់គ្រងដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- ជំរុញការឆ្វៀលដីស្បែកខ្លា ជូនប្រជាពលរដ្ឋ និងការដោះស្រាយសំណង់លើទឹក លើឆ្នេរ លើដីចំណីឆ្នេរ កោះរ៉ុង ក្រុងព្រះសីហនុ ព្រមទាំងរៀបចំប្លង់គោលសមាហរណកម្មដីប្រជាពលរដ្ឋ ដីវិនិយោគ ដីអភិរក្ស ដើម្បីធានាការអភិវឌ្ឍ និងការអភិរក្សប្រកបដោយចីរភាព
- ជំរុញរៀបចំបញ្ចប់ផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រក្រុងព្រះសីហនុ ចំនួន ០៦ តំបន់ឆ្នេរ
- ជំរុញរៀបចំវេទិកាអចិន្ត្រៃយ៍ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ជំរុញរៀបចំសិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងលើកប៉ាណូផ្សព្វផ្សាយសារាចរលេខ០១ ស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ជំរុញរៀបចំច្បាប់ និងអនុក្រឹត្យព្រមទាំងបទដ្ឋានគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ។

## VII-ការងាររៀបចំដែនដី

- មន្ទីរដ.ន.ស.ស.រាជធានី-ខេត្ត ត្រូវផ្តួចផ្តើមលើកសំណើទៅសាលារាជធានី-ខេត្ត ដើម្បីបង្កើតគណៈកម្មការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបង្កើតលេខាធិការដ្ឋានមួយ ដោយមានមន្ត្រីជំនាញធ្វើការអចិន្ត្រៃយ៍ដោយសម្រេចឱ្យបានក្នុងឆមាសទី១ ឆ្នាំ២០១៦
- ជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំផែនការការងារ និងផែនការកញ្ចប់ថវិកាដើម្បីអនុវត្ត និងរកដៃគូសហការ និងគាំទ្រស្របតាមធនធាន និងលទ្ធភាព
- ពង្រឹងនីតិវិធីនៃការគ្រប់គ្រងថវិកាក្រោមការទទួលខុសត្រូវផ្ទាល់របស់នាយកដ្ឋានជំនាញ ដើម្បីពន្លឿនការអនុវត្តកម្មវិធីថវិកាទាន់ពេលវេលា និងប្រកបដោយការទទួលខុសត្រូវខ្ពស់
- ថ្នាក់ជាតិបន្តពិភាក្សាគ្នាអំពីនីតិវិធីក្នុងការកសាងកញ្ចប់ថវិកាក្នុងការរៀបចំប្លង់គោល ដែលអាចមាន២ជម្រើស គឺទី១-រៀបចំផ្អែកតាមទំហំការងារ ចំនួនមនុស្សនិងរយៈពេលបំពេញការងារ ទី២-យកលំអានចុះបញ្ជីដីរដ្ឋដោយគិតផ្អែកតាមក្រឡាផ្ទៃ។

- ឆ្លើយតបទៅនឹងកង្វល់របស់សាលារាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការខូចខាតហេដ្ឋារចនាសម្ព័ន្ធ បណ្ដាលមកពីការអភិវឌ្ឍរបស់វិស័យឯកជន ដូចជា ផ្លូវ លូ ជាដើម គឺអាចដោះស្រាយតាមរយៈការបង្កើតជាមូលនិធិហេដ្ឋារចនាសម្ព័ន្ធដែលមានចែងនៅក្នុងសេចក្ដីព្រាងច្បាប់សំណង់
- ស្នើបង្កើតក្រុមការងារអន្តរក្រសួងដើម្បីវាយតម្លៃការប្រឡងប្រណាំងលើការងាររៀបចំប្លង់គោល និងស្នើសុំឱ្យមានក្រុមការងារតាមដានអភិវឌ្ឍ និងអនុម័តប្លង់គោលដែលបានអនុម័តរួចដើម្បីតាមដាននិងវាយតម្លៃ។

## VIII-ការងារលំនៅឋាន

- អគ្គនាយកដ្ឋានរដ្ឋបាល ត្រូវពិនិត្យជ្រើសរើសក្របខ័ណ្ឌថ្មីបន្ថែមទៀតសម្រាប់អគ្គនាយកដ្ឋានលំនៅឋាន
- បន្តប្រមូលទិន្នន័យនិងព័ត៌មានអំពីលំនៅឋានបណ្ដោះអាសន្ន និងតម្រូវការលំនៅឋានជាក់ស្ដែងនៅតាមទីក្រុង ទីប្រជុំជន ដែលប្រជាពលរដ្ឋកំពុងប្រឈមបញ្ហាខ្វះលំនៅឋាននៅទីតាំងអាទិភាពចាំបាច់
- បន្តផ្សព្វផ្សាយគោលនយោបាយជាតិស្ដីពីលំនៅឋាន សារាចរលេខ ០៣ ស្ដីពីការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន និងកម្មវិធីលំនៅឋានសាធារណៈជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋឱ្យបានជ្រួតជ្រាប
- បន្តរៀបចំប្លង់គំរូលំនៅឋានសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប ចំណូលមធ្យម និងជនងាយរងគ្រោះ
- ពង្រឹង និងពង្រីកទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន ដើម្បីធ្វើកិច្ចសហប្រតិបត្តិការលើកិច្ចការលំនៅឋាន ទាំងផ្នែកបច្ចេកទេស ក្របខ័ណ្ឌគតិយុត្ត និងការកសាងសមត្ថភាពមន្ត្រី។

## IX-ការងារច្បាប់

- បង្កើតក្រុមការងារចំពោះកិច្ច (ក្រុមការងារតាក់តែងលិខិតបទដ្ឋានគតិយុត្ត) គាំទ្រដល់ក្រុមការងារអភិវឌ្ឍនិងផ្សព្វផ្សាយគោលនយោបាយនិងច្បាប់និងនាយកដ្ឋាននីតិកម្ម ដើម្បីពន្លឿនការរៀបចំតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពិសេសទាក់ទងនឹងការងារដែលមានហានិភ័យ
- រៀបចំបញ្ជីតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅក្នុងឆ្នាំ២០១៦ ជាពិសេស បញ្ជីនៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំណង់ដែលមានហានិភ័យ និងបញ្ជីដែលត្រូវរៀបចំរយៈពេលវែង
- បន្តបណ្ដុះបណ្ដាល និងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ឱ្យអនុវត្តដល់អ្នកប្រតិបត្តិច្បាប់និងអ្នកពាក់ព័ន្ធ។

## X-ការងាររដ្ឋបាលទូទៅ

### ១-វិធានការត្រួតពិនិត្យយន្តការនៃការផ្ដល់សេវាសាធារណៈ

- ធ្វើការវាយតម្លៃឡើងវិញទាំងមធ្យោបាយធ្វើការងារ និងមន្ត្រីបំពេញការងារអំពីប្រសិទ្ធភាពការងារ ដើម្បីធ្វើការកែសម្រួល
- ការិយាល័យច្រកចេញចូលតែមួយត្រូវសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរិះរកយន្តការដែលបង្កលក្ខណៈងាយស្រួល និងបានឆាប់រហ័សក្នុងការពិនិត្យបញ្ជាក់ និងសម្រេចលើសំណើសុំសេវា។

- ការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើការបូកសរុបបញ្ជីរាយមុខសេវាដែលមិនទាន់មាននៅក្នុងកម្រងសេវាផ្លូវការ ដើម្បីដាក់ឆ្លងសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួង និងលើកស្នើសុំធ្វើវិសោធនកម្មប្រកាសរួមលេខ៩៩៥ និង៩៩៦។ គួរមានការពិភាក្សាផ្នែកច្បាប់ដើម្បីអាចឱ្យមានការចូលរួមពីភ្នាក់ងារឯកជនជាអ្នករៀបចំឯកសារគម្រោងតំណាងឱ្យម្ចាស់គម្រោងនៅក្នុងដំណើរការនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាត។

**២-ការងារគ្រប់គ្រងមន្ត្រីនិងវិធានការអនុវត្តសហលក្ខន្តិក្កៈមន្ត្រីរាជការស៊ីវិលរបស់ក្រសួង និងវិធានការពង្រឹងស្ថាប័ន**

- គ្រប់អង្គភាពត្រូវពង្រឹងបន្ថែមលើការស្រង់វត្តមានមន្ត្រីឱ្យបានជាក់លាក់ និងត្រួតពិនិត្យសកម្មភាពបំពេញការងារ និងបង្កើតតារាងតាមដានការងារ រួមជាមួយរបាយការណ៍លទ្ធផលការងារប្រចាំខែ
- គ្រប់អង្គភាពត្រូវរំលឹកដាស់តឿន និងជំរុញមន្ត្រីឱ្យបំពេញការងារទៀងទាត់តាមតួនាទី និងភារកិច្ច និងត្រូវស្នើចាត់វិធានការលើមន្ត្រីដោយអនុវត្តឱ្យស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- នាយកដ្ឋានបុគ្គលិក ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីឱ្យចំមុខសញ្ញា
- ការិយាល័យច្រកចេញចូលតែមួយត្រូវតែមានមន្ត្រីប្រចាំការរៀងរាល់ម៉ោងធ្វើការ និងដាក់ការទទួលខុសត្រូវខ្ពស់និងអចិន្ត្រៃយ៍ និងរៀបចំកន្លែងទទួលសេវាឱ្យបានសមស្របតាមស្តង់ដារ
- ត្រូវពិនិត្យមន្ត្រីដែលមានស្រាប់ឡើងវិញ ទាំងមន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា ហើយធ្វើផែនការតម្រូវការក្របខ័ណ្ឌដាក់ស្តែងស្នើសុំក្រសួងដើម្បីបំពេញកង្វះខាតមន្ត្រី
- គ្រប់អង្គភាពទាំងអស់ត្រូវយកចិត្តទុកដាក់ថែរក្សាសម្ភារៈបច្ចេកទេស និងត្រូវមានផែនការជាមុនក្នុងការជួសជុល ឬផ្លាស់ប្តូរជាដំណាក់កាលៗ
- ត្រូវយកចិត្តទុកដាក់លើទីតាំងផ្ទុកឯកសារឱ្យមានសុវត្ថិភាព។ មន្ទីរត្រូវខិតខំដោះស្រាយទីតាំងផ្ទុកឯកសារឱ្យអស់លទ្ធភាព។

**៣-ការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយដើម្បីពង្រឹងជំនាញវិជ្ជាជីវៈរបស់មន្ត្រី** : ក្រសួង និងមន្ទីរដ.ន.ស.ស រាជធានី-ខេត្ត ត្រូវបន្តរៀបចំផែនការបណ្តុះបណ្តាលនិងផ្សព្វផ្សាយបន្តដើម្បីឱ្យជ្រួតជ្រាបដល់អាជ្ញាធរពាក់ព័ន្ធ មន្ត្រីជំនាញ និងសហគមន៍នៅមូលដ្ឋាននិងឱ្យមាននិរន្តរភាព និងការទទួលខុសត្រូវ។

**៤-ការងាររដ្ឋបាលទូទៅ និងការងារព័ត៌មាន**

- របាយការណ៍ និងឯកសារផ្សេងៗដែលត្រូវផ្តល់ឱ្យអ្នកសរុបត្រូវតែផ្តល់ជាដាច់ខាតតាមកាលបរិច្ឆេទកំណត់ និងត្រូវរៀបចំខ្លឹមសារពិស្តារចំកម្មវត្ថុដែលស្នើសុំ
- មន្ទីរនីមួយៗត្រូវមានក្រុមព័ត៌មាន និងប្រតិកម្មរហ័ស និងអ្នកនាំពាក្យដោយត្រូវតាមដានប្រចាំថ្ងៃអំពីព័ត៌មានទាក់ទងនឹងសមត្ថកិច្ចរបស់ខ្លួនដែលកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងត្រូវធ្វើប្រតិកម្មទៅបណ្តាញសារពត៌មានភ្លាមៗទាន់ពេលដោយជូនដំណឹងមកក្រសួងបានជ្រាប
- ត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណៈជនតាមគ្រប់រូបភាព។

**៥-ការងារសវនកម្ម និងអធិការកិច្ច**

- គ្រប់អង្គភាពត្រូវអនុវត្តតាមអនុសាសន៍របស់សវនករ ដើម្បីកែលម្អអនុវត្តឱ្យបានប្រសើរ និងចៀសវាងប្រព្រឹត្តកំហុសឆ្គងដដែលៗដោយមន្ត្រី ឬអង្គភាពដដែលៗ
- ស្នើសុំដាក់ករណីខុសឆ្គងជូនក្រុមប្រឹក្សាវិន័យពិនិត្យ និងមានវិធានការជាប្រចាំ។៚

**៦-វិធានការអនុវត្តការគ្រប់គ្រងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

- ការលើកផែនការត្រូវធ្វើឱ្យស្របតាមតួនាទី និងភារកិច្ចរបស់អង្គភាព ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ផែនការរបស់ក្រសួង ផែនការរបស់អង្គភាព និងឱ្យសមល្មមដែលអាចអនុវត្តទៅបាន
- ត្រូវធ្វើផែនការលំអិតប្រចាំត្រីមាសសម្រាប់អនុវត្តឱ្យបានឆាប់រហ័ស និងប្រគល់ភារកិច្ចដល់ថ្នាក់ផ្នែក ឬការិយាល័យ លើកសុំអនុវត្តសកម្មភាពនីមួយៗ ដែលជាការទទួលខុសត្រូវរបស់ថ្នាក់នោះដំបូងគេ
- ប្រាក់បៀវត្សត្រូវបានបើកផ្តល់តាមប្រព័ន្ធធានាគារ១០០%។ ប្រាក់រង្វាន់ពីកម្រៃសេវា ប្រាក់លាភការផ្សេងៗ ប្រាក់បេសកកម្មក្នុង និងក្រៅប្រទេស ត្រូវធ្វើការបើកផ្តល់តាមប្រព័ន្ធធនាគារ។ ប្រាក់រង្វាន់ទេយ្យបុរេប្រទាន ប្រាក់បុរេប្រទាន និងប្រាក់ទូទាត់ត្រង់ត្រូវផ្តល់ទៅអង្គភាពថវិកាសាមី ត្រូវធ្វើការផ្ទេរតាមប្រព័ន្ធធនាគារ ដើម្បីអង្គភាពថវិកាចាត់ចែងបន្ត (មិនបើកផ្តល់ដោយផ្ទាល់ពីនាយកដ្ឋានហិរញ្ញកិច្ចទៅមន្ត្រី ឬអង្គភាពក្រោមឱវាទអង្គភាពថវិកាណាមួយឡើយ)។

**៧-ការផ្ទេរមុខងារ និងធនធានឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** ស្នើសុំឱ្យគ្រប់ផ្នែកជំនាញទាំងអស់ ពិនិត្យឡើងវិញពីមុខងារដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ និងកំពុងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងបន្តសហការ និងពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ (គ.ជ.អ.ប) ដើម្បីពិនិត្យមើលមុខងារបន្ថែមទៀត ដើម្បីផ្ទេរ ឬផ្ទេរសាកល្បង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ អស់លោក លោកស្រី មេត្តាជ្រាបជារបាយការណ៍ និងសហការអនុវត្តតាមការគួរ។៚

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ